# "ផ្ចាញ់មារ" ក្នុងសិល្បៈគំនូរពុទ្ធប្រវត្តិ

ពុទ្ធសាសនិកទូទៅប្រាកដជាធ្លាប់ឮនិងស្គាល់ពាក្យថា "ផ្ចាញ់មារ" ឬ "មារវិជ័យ" ដែលមានដំណើរដើមហេតុរៀបរាប់ក្នុងរឿងពុទ្ធប្រវត្តិ។ បច្ច័យនាំឱ្យស្គាល់រឿងនេះ ប្រហែលដោយសារវប្បធម៌ខ្មែរតែងលើករឿងនេះបង្ហាញរឿយៗតាមរបៀបច្រើនយ៉ាងដូចជា ការសម្តែងបង្ហាញក្នុងបុណ្យអភិសេកព្រះពុទ្ធរូបសាងថ្មី ឬការស្តាប់ព្រះសង្ឃសម្តែងព្រះធម្មទេសនាព្រះធម្មត្រាស់ ឬការសាងព្រះបដិមាព្រះពុទ្ធផ្ចាញ់មារ(ភូមិស្បូស) និងជាពិសេសបំផុតគឺការនិយមសាងគំនូរព្រះពុទ្ធផ្ចាញ់មារក្នុងព្រះវិហារ។ មិនតែប៉ុណ្ណោះ ក្នុងសង្គមខ្មែរច្រើនបង្ហាញភ្ជាប់អន្ទើព្រះពុទ្ធផ្ចាញ់មារនឹងតួអង្គសំខាន់មួយទៀតគឺ "នាងគង្ហីង" ដែលគេដឹងថា ជាការនិយមបន្ថែមក្នុងសិល្បៈបណ្តាប្រទេសកាន់ពុទ្ធសាសនានៅអាស៊ីអាគ្នេយ៍ផ្សេងទៀតដែរ (រូបលេខ១-២)។[1]





រូបលេខ១ នាងគង្ហីងក្នុងចម្លាក់ផ្ចាញ់មារលើជញ្ជាំងក្បែរចេតិយ Swedagon នៅមីយ៉ាន់ម៉ា  រូបលេខ២ គំនូរផ្ចាញ់មារនិងវត្តមាននាងគង្ហីងក្នុងសិល្បៈឡាវ (ប្រភព៖ Surapee Muen art aa-saa)

ជាការពិតក្នុងសិល្បៈខ្មែរ បើពោលតែអំពីចម្លាក់ និងគំនូរបង្ហាញពីឈុតផ្ចាញ់មារ គេឃើញមានតាំងពីបុរាណកាលមកដូចជា ចម្លាក់ហោជាងប្រាសាទបន្ទាយក្តី នៅខេត្តសៀមរាប និងហោជាងប្រាសាទវត្តនគរបាជ័យ នៅខេត្តកំពង់ចាម(ស.វ.ទី១២) ព្រមទាំងប្រាសាទផ្សេងទៀតដែលឧទ្ទិសដល់ពុទ្ធសាសនា។ តាមចំណោះចំណាំរឿងពុទ្ធប្រវត្តិរៀបរាប់ដំណើរផ្ចាញ់មារនោះថា ខណៈព្រះសម្មាសម្ពុទ្ធកំពុងគង់ធ្វើសមាធិស្វែងរកមោក្ខធម៌

[1] សូមអានបន្ថែម៖ អំពីពាក្យ "គង្ហីង" ដោយ៖ ហ៊ុន ឈុនតេង, ផ្សាយលើគំណ https://khmercivilization.ams.com.kh/detail/2863 (១១ កក្កដា ២០២១)

អត្ថបទដោយ៖ ហឿន សុវណ្ណមរកត

ក្រោមដើមពោធិព្រឹក្ស មារាធិរាជជាស្តេចនៃពួកមារ បានប្រើល្បិចគ្រប់យ៉ាងចាប់តាំងពីឱ្យបុត្រីទាំងបីរបស់ខ្លួនមកប្រើកាមគុណលួងលោម រហូតកូនមារទាំង៣នាក់ទទួលបាបក្លាយជាចាស់ទ្រុឌទ្រោមគ្រាំគ្រាដើរចេញទៅ។[2] សាច់រឿងនេះ គេឃើញមានគំនូរបុរាណនៅវត្តកំពង់ត្រឡាចលើ ស្ថិតក្នុងខេត្តកំពង់ឆ្នាំង និងគំនូរលើហប់ខ្យល់ក្នុងព្រះវិហារវត្តទ្រាំង ក្នុងខេត្តកណ្ដាលជាដើម (រូបលេខ១៣-៤)។



រូបលេខ១៣-៥ កាលនាងកូនមារទាំងបីមកផ្ចាញ់ព្រះអង្គ ហើយទៅជាចាស់ទាំងអស់គ្នា
(គំនូរបុរាណវត្តកំពង់ត្រឡាចលើ, ដើមស.វ.ទី២០ និងគំនូរលើហប់ខ្យល់ព្រះវិហារវត្តទ្រាំង, ឆ្នាំ១៩៤០)

[2] ព្រាប ចាន់ម៉ារ៉ា, ២០១៥: ទំ.២៤-៣០

អត្ថបទដោយ៖ ហៀន សុវណ្ណមរកត

ក្នុងអវិទូរេនិទានបន្តថា គ្រានោះមារាធិរាជ (វសវត្តីមារ) មានចិត្តក្ដៅក្រហាយ ព្រោះដឹងថាបើព្រះអង្គបានត្រាស់ នោះនឹងរួចផុតពីអំណាចរបស់ខ្លួន ហើយថែមទាំងនាំអ្នកដទៃឱ្យរួចផុតដែរ។ ស្ដេចមារ បានកេណ្ឌពលយ៉ាងច្រើនសន្ធឹកសន្ធាប់មើលទៅគួរឱ្យខ្លាចរកទីបំផុតគ្មាន ខ្លះមានមុខមាត់ប្លែកៗ ពណ៌ខុសៗគ្នា ខ្លះខៀវ ខ្លះលឿង ខ្លះក្រហម ខ្លះមានខ្លួនជាមនុស្ស ក្បាលជាសត្វ (ដំរី សេះ នាគ) សម្រុកចូលមកដើម្បីបំផ្លាញដំណើរត្រាស់ដឹងរបស់ព្រះពោធិសត្វ (រូបលេខ២៦)។ ពេលនោះពពួកទេវតានិងព្រហ្មទាំងឡាយដែលធ្លាប់មកចោមរោមបម្រើ និងបូជាថ្វាយព្រះអង្គ បានកើតសេចក្ដីភ័យខ្លាចយ៉ាងខ្លាំង ហើយបានរត់ទៅកាន់ទីកន្លែងរៀងៗខ្លួនអស់ ដោយទុកឱ្យព្រះពោធិសត្វគង់នៅមួយព្រះអង្គឯង (រូបលេខ២៧)។ មារាធិរាជបានគិតថា ខ្លួនគ្មានសត្រូវណាអាចតទល់បានទេ ព្រោះគ្មាននរណាម្នាក់នៅសេសសល់ជួយព្រះអង្គឡើយ។ ប៉ុន្តែព្រះពោធិសត្វមិនតក់ស្លុត ព្រះអង្គទ្រង់នឹករំពឹងនូវបារមីទាំង១០ ស្រេចហើយក៏គង់ស្ងៀម (រូបលេខ២៨)។[3]



រូបលេខ២៦ គំនូរបុរាណលើហប់ខ្យល់វត្តចិនដំដែក គូរបង្ហាញពីពួកមារលើកវេហ៍ពលមកផ្ចាញ់ព្រះអង្គ



រូបលេខ២៧ គំនូរក្នុងព្រះវិហារវត្តស៊ីសុវត្ថិរតនារាម គូរបង្ហាញពពួកទេវតា ចាកចោលព្រះអង្គ



រូបលេខ២៨ គំនូរវត្តអំពិល បង្ហាញព្រះអង្គគង់សមាធិស្ងៀមចំពោះមុខមារ

[3] គណៈកម្មការធម្មវិន័យ, ២០១៣: ៤១-៤៨

អត្ថបទដោយ៖ ហៀន សុវណ្ណមរកត

ដោយឃើញព្រះអង្គគង់ស្ងៀមលើបល្ល័ង្កវ័ត្ន ស្តេចមារបានស្រែកប្រកាសដណ្តើមបល្ល័ង្កវ័ត្នពីព្រះអង្គ ដោយសម្អាងខ្លួនមានសេនា និងរេហ៍ពលជាច្រើនធ្វើជាសាក្សីបញ្ជាក់ថាបល្ល័ង្កនោះជារបស់ខ្លួន។ មារបានសួរទៅព្រះអង្គថា តើព្រះអង្គមាននរណាធ្វើជាសាក្សីដើម្បីបញ្ជាក់ពីបារមី និងទានបារមីដែលព្រះអង្គបានសន្សំមក?(រូបលេខ៩-១០)។ ព្រះអង្គមិនមានមនុស្ស ឬសត្វណាម្នាក់នៅទីនោះធ្វើជាសាក្សីឡើយ។ ព្រះអង្គក៏បានលើកឡើងពីទានបារមីដែលព្រះអង្គធ្លាប់សាងកាលពីជាតិមុនៗ ជាពិសេសគឺកាលដែលព្រះអង្គកើតជា **ព្រះវេស្សន្តរពោធិសត្វ** ដែលបានធ្វើមហាទានរហូតដល់ទៅ១០៧ដង ហើយព្រះអង្គតែងប្រូចទឹកលើព្រះធរណីរាល់ពេលសាងអំពើជាកុសលទាំងឡាយនោះ ដូច្នេះមានតែព្រះធរណីជាសាក្សីស្រាប់។ ភ្លាមនោះ ព្រះអង្គបានចង្អុលព្រះហស្តចុះទៅដី ផែនដីទាំងមូលកក្រើកញាប់ញ័រ ស្រាប់តែនាងគង្ហីងព្រះធរណីចេញមកធ្វើជាសាក្សីបញ្ជាក់ពីមហាទានរបស់ព្រះអង្គ ដោយបានច្បូតសក់បញ្ចេញទឹកក្លាយជាសមុទ្រដ៏ធំ បណ្តាលឱ្យពួកមារទាំងអស់ត្រូវលិចលង់ និងវិនាសស្លាប់រប៉ាត់រប៉ាយ (រូបលេខ១០)។[4]



រូបលេខ៩-១១ គំនូរវត្តវង្គដ្ឋបុរី បង្ហាញព្រះអង្គគង់លើបល្ល័ង្កវ័ត្ន ដោយមានមារប្រកាសដណ្តើម តែមាននាងគង្ហីងព្រះធរណីជាសាក្សីព្រះអង្គចេញមកច្បូតទឹក (គំនូរឆ្នាំ២០២២)

ក្រោយទឹកជោរជន់ជាមហាសាគរហើយ តាមរយៈគំនូរតាមវត្តខ្លះបង្ហាញឱ្យឃើញពួកមារវិនាសអន្តរធាន មានពពួកសត្វឆ្មាម មករ ពិន្ទង់ ក្រពើ ក្រពត និងត្រីផ្សេងៗដេញខាំត្របាក់ពួកមារមានចិត្តបាបទាំងអម្បាលឱ្យបាក់បបខ្ទបខ្ទាច ចុះចាញ់ព្រះសម្មាសម្ពុទ្ធ

[4] ប៉ាង ខាត់, ១៩៦១: ១-១៨ និង សាន ផល្លា, ២០០៧: ២៨

អត្ថបទដោយ៖ ហៀន សុវណ្ណមរកត

ដែលទ្រង់ធម៌បរិសុទ្ធក្នុងគ្រានោះទៅ។ ក្នុងសិល្បៈគំនូរតាមវត្ត គេច្រើនគូរទិដ្ឋភាពត្រង់អន្ទើនេះនៅខាងក្រោយបាល្ល័ង្កព្រះដើរធំក្នុងព្រះវិហារ។ ទន្ទឹមនោះ គំនូរវត្តខ្លះច្រើនគូរបង្ហាញជាពីរផ្នែក គឺព្រះពុទ្ធគង់លើបាល្ល័ង្ករ័ត្នខ្ពស់ មាននាងគង្ហីងច្របូតសក់នៅមុខបាល្ល័ង្ក ហើយពពួកមារនៅម្ខាងលើករេហ៍ពលដេរដាសមកដណ្តើមបាល្ល័ង្ករ័ត្ន និងពពួកមារនៅម្ខាងទៀត បង្ហាញកាយវិការចុះចាញ់បារមីព្រះអង្គដោយលើកដៃប្រណម្យ ថ្វាយផ្កាឈូកជាដើម (រូបលេខ១២-១៦)។



រូបលេខ១២-១៤ គំនូរវត្តវង្គដ្ឋបុរីបង្ហាញពីពពួកមារត្រូវវិនាសដោយទឹកជន់លិច



រូបលេខ១៥-១៦ គំនូរព្រះពុទ្ធផ្ចាញ់មារគូរនៅព្រះវិហារបុរាណវត្តពុទ្ធា និងវត្តព្រះធាតុបាស្រី

បន្ទាប់ពីពពួកមារត្រូវវិនាសបរាជ័យអន្តរធានអស់ទៅ ពួកទេវតា ព្រហ្ម នាគ និងគ្រុឌទាំងឡាយបានឃើញពីជ័យជម្នះដ៏អស្ចារ្យរបស់ព្រះអង្គ ហើយត្រេកអរសាទរ នាំគ្នាក្រាបថ្វាយបង្គំ បូជាផ្កាភ្ញី ព្រមទាំងពោលពាក្យសរសើរ ថ្វាយព្រះពរដល់ព្រះពុទ្ធអង្គដែលមានជ័យជម្នះលើមារចិត្តបាប។ រឿងរ៉ាវបានបញ្ចប់ដោយការគោរពបូជាចំពោះព្រះបារមីដ៏ខ្ពង់ខ្ពស់របស់ព្រះអង្គ ដែលបានត្រាស់ដឹងជាព្រះពុទ្ធក្នុងលោក ព្រមដោយពួកទេវតាទាំងឡាយបាចផ្កាបូជាព្រោងព្រាត ធ្លាក់ដេរដាសពាសពេញនៅជិតពោធិមណ្ឌល ទ្រង់គង់ពត់ព្រះភ្នែនពែនព្រះបាទស្អាតបរិសុទ្ធ តាំងសមាធិបម្រុងឱ្យបានត្រាស់ដឹងនៅក្នុងថ្ងៃនេះកុំបីខានឡើយ។

អត្ថបទដោយ៖ ហៀន សុវណ្ណមរកត

សូមបញ្ជាក់ថា គំនិតយល់ថាមារជាសភាវៈអាក្រក់នេះ ដក់ជាប់ចិត្តពុទ្ធសាសនិកខ្មែរជានិច្ច។ ក្នុងសង្គមប្រវត្តិសាស្ត្រខ្មែរទសវត្សរ៍ទី៧០ គេបានគូរប្រដូចកងទ័ពវៀតណាមកុម្មុយនីស្តនិងពួកពលបរិវាជាមារដោយសរសេរថា "ទមិឡអន្សរត្ថិយ៍ជាមារត្រូវតែវិនាស" ធ្វើជាការផ្សព្វផ្សាយសារនយោបាយ (រូបលេខ១៧)។ មិនតែប៉ុណ្ណោះ នៅក្នុងទសវត្សរ៍ទី៨០ គេបានគូរបង្ហាញអំពីបដិវត្តសម័យកម្ពុជាប្រជាធិបតេយ្យលើបាល័ង្កខាងក្រោយព្រះជីវ័ក្នុងព្រះវិហារវត្តកំពង់ធំ(ព្រះវិហារបានរុះរើឆ្នាំ២០១៧) ប្រហែលគំនិតសិល្បៈនេះទុកជានិមិត្តរូបនៃពួកមារបំផ្លាញសង្គមសាសនា និងទុកជាការចងចាំផងដែរ (រូបលេខ១៨)។[5]





រូបលេខ១៧-១៨ គំនូរទសវត្សរ៍ទី៧០-៨០ ប្រៀបធៀបកងទ័ពបដិវត្តជាមារ (ប្រភពរូបលេខ១៧៖ F. Bizot)

សរុបសេចក្តីមក គំនូរពុទ្ធប្រវត្តិអន្លើ "ផ្ចាញ់មារ" ឬ "មារវិជ័យ" មិនត្រឹមតែជាសិល្បៈសាសនាដ៏មានប្រជាប្រិយភាពក្នុងការឆ្លុះបញ្ចាំងពីជ័យជម្នះ នៃព្រះធម៌លើសភាវអាក្រក់ដោយមានវត្តមានរបស់នាងគង្ហីងព្រះធរណីជាសាក្សីទេ តែក៏ជាកញ្ចក់ឆ្លុះបញ្ចាំងដល់ឥទ្ធិពលនៃប្រវត្តិសាស្ត្រសង្គមខ្មែរផងដែរ។ ការវិវត្តនៃគំនិតសិល្បៈនេះចាប់តាំងពីចម្លាក់ហោជាងប្រាសាទបុរាណ រហូតដល់គំនូរលើជញ្ជាំងព្រះវិហារ និងផ្ទាំងរូបភាពឃោសនានយោបាយក្នុងទសវត្សរ៍ឆ្នាំ១៩៧០ និង១៩៨០ បានបង្ហាញយ៉ាងច្បាស់ថា សង្គមខ្មែរតែងតែដកស្រង់និងប្រើប្រាស់និមិត្តរូប "ពួកមារ" ប្រៀបធៀបទៅនឹងកម្លាំងបំផ្លិចបំផ្លាញ ឬខ្មាំងសត្រូវឈ្លានពាន។

[5] Ian Harris, 2005: 49-80

អត្ថបទដោយ៖ ហៀន សុវណ្ណមរកត

# ឯកសារយោង

ប៉ាង ខាត់

១៩៦១, "ពុទ្ធជីវប្បវត្តិ", *កម្ពុជសុរិយា, ឆ្នាំទី៣៣ លេខ១,* ទំ.១-១៨, ពុទ្ធសាសនបណ្ឌិត្យ, ភ្នំពេញ

ព្រាប ចាន់ម៉ារ៉ា

២០១៩, "ផ្កាញីមារ", *កម្រងអត្ថបទក្នុងបណ្ដាញពត៌មានវប្បធម៌ខ្មែរ,* លេខ១០, ទំ.២៤-៣០, យសោធរ, ភ្នំពេញ

សាន ផល្លា

២០០៧, *គំនូរតាមវត្ត,* រ៉ៃយំ, ភ្នំពេញ

ហ៊ុន ឈុនតេង

២០២១, "អំពីពាក្យ "គង្ហីង"" ផ្សាយលើគំណ [https://khmercivilization.ams.com.kh/detail/2863](https://khmercivilization.ams.com.kh/detail/2863) (១១ កក្កដា ២០២១)

Ian Harris

2005, *Cambodian Buddhism; History and Practice*, University of Hawai'i Press, USA